ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខៈ ២៣៣៩ ប្រ.ក

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងគ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះ

************

## សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យការនាំចូល ការផលិត ការទិញដូរ ការចែកចាយ និងការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ

-បានឃើញប្រកាសអន្តរក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ លេខ ៧៩២ ប្រ.ក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ១៩៩៩

តាមការចាំបាច់ ក្នុងការធានាស្ថេរភាព សុវត្ថិភាព សន្តិសុខ សាធារណៈ

## សម្រេច

**ប្រការ១.-** អាជីវករ ដែលធ្វើអាជីវកម្មលើសេវាគ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះ និង បណ្តាក្រុមហ៊ុនដែល

កន្លងមកមាន អាជ្ញាប័ណ្ណ អោយប្រកបរបរនាំចូលគ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះ សំរាប់យកមកបែងចែង បំរើសេវាកម្មសាធារណៈ ឬ វិស្វកម្មស៊ីវិល នៅក្នុងប្រទេស ត្រូវសុំច្បាប់អនុញ្ញាតជាថ្មីមកក្រសួងមហាផ្ទៃ តាមរយៈអគ្គស្នងការនគរបាលជាតិ ។

ប្រការ២.- រាល់ការនាំចូលនូវ គ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះ ត្រូវធ្វើសំណើមកអគ្គស្នងការនគរបាលជាតិ តាមរយៈ នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និង អគ្គីភ័យ ដោយបញ្ជាក់អំពីប្រភេទ បរិមាណ គុណភាព ប្រសិទ្ធភាព និង តំរូវការក្នុងការនាំចូល ។

ប្រការ៣.- មុនពេលគ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះទាំងនោះមកដល់ព្រំដែន កំពង់ផែ ឬ ព្រលានយន្តហោះ ម្ចាស់ទំនិញ ត្រូវធ្វើសេចក្ដីរាយការណ៍មកអគ្គស្នងការនគរបាលជាតិ តាមរយៈ នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះនិងអគ្គីភ័យ ដើម្បីចាត់វិធានការត្រួតពិនិត្យ ចុះបញ្ជីការគ្រប់គ្រងតាមដាន និង ធ្វើបែបបទដឹកជញ្ជូន ព្រមទាំងចាត់មន្ត្រីជំនាញអមការពារសុវត្ថិភាពមុខទំនិញទាំងនោះរហូតបញ្ចូលក្នុងឃ្លាំងសុវត្ថិភាព ។

ប្រការ៤.- ឃ្លាំងសំរាប់ស្តុក គ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះ ត្រូវមានទីតាំងដាច់ឆ្ងាយពីភូមិដ្ឋាន រមណីយដ្ឋាន វត្តអារាម ទីប្រជុំជន ផ្លូវជាតិ អាគារសំណង់ ការដ្ឋាន និង ទីធ្លាសាធារណៈ ត្រូវមានប្រពន្ធ័ការពារសុវត្ថិភាព ធានា និរភ័យ មានរបង សោទ្វាររឹងមាំ និងត្រូវមាន ឆ្មាំដែលមានប្រវត្តិរូបច្បាស់លាស់ យាមប្រចាំការ ២៤ ម៉ោងលើ ២៤ ម៉ោង ។ នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះនិងអគ្គីភ័យមានភារៈកិច្ចណែនាំត្រួតពិនិត្យបញ្ហានេះ ។

ប្រការ៥.- ភាពមិនប្រក្រតី ឬ ឧបទ្ទវហេតុផ្សេងៗ ដែលកើតមានឡើងពាក់ពន្ធ័ដល់ការគ្រប់គ្រងគ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះ នាយឆ្មាំ ឬ អ្នកទទួលខុសត្រូវ ត្រូវរាយការណ៍ជាបន្ទាន់ដល់អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិត និង មកនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះនិងអគ្គីភ័យ ដើម្បីមានវិធានការ ។

ប្រការ៦.- រាល់ការបញ្ចូល - បញ្ចេញពីឃ្លាំងស្តុកនូវគ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះ ត្រូវចុះបញ្ជីតាមគំរូដែល នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និង អគ្គីភ័យ បើកផ្ដល់ជូន ដើម្បីងាយស្រួលដល់ការតាមដានត្រួតពិនិត្យ ។

ប្រការ៧.- គ្រប់ការដ្ឋានផលិតថ្ម ឬ ការដ្ឋានស្រាវជ្រាវរ៉ែ ឬ ការដ្ឋានធ្វើអាជីវកម្ម សិប្បកម្មដែលមានអាជ្ញាប័ណ្ណអនុញ្ញាត ពីក្រសួង ស្ថាប័ន ដែលពាក់ពន្ធ័ ប៉ុន្តែចាំបាច់ត្រូវប្រើប្រាស់គ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះ ត្រូវសុំអាជ្ញាប័ណ្ណអនុញ្ញាតប្រើប្រាស់ ឬ ឈប់ប្រើប្រាស់គ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះ មកអគ្គស្នងការដ្ឋាននគរបាលជាតិ តាមរយៈនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និង អគ្គីភ័យ ។

ប្រការ៨.- ការលក់ ការផ្ដល់ ការចែកចាយនូវគ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះ អាចធ្វើបានចំពោះតែការដ្ឋាន អាជីវកម្ម សិប្បកម្ម និង បណ្ដាអង្គការណាដែលមានអាជ្ញាប័ណ្ណ អោយប្រើប្រាស់គ្រឿងផ្ទុះ ជាតិផ្ទុះ

សារធាតុផ្ទុះ ពីអគ្គស្នងការដ្ឋាននគរបាលជាតិប៉ុណ្ណោះ ។ រាល់សំណើសុំទិញត្រូវឆ្លងកាត់នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គិភ័យ ។ ក្នុងករណីមានជនចំឡែក មិនច្បាស់លាស់ មកទាក់ទងសុំទិញ ឬ ចែកចាយ ត្រូវរាយការណ៍ជាបន្ទាន់ដល់អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិត ឬ មកនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និង អគ្គីភ័យ ។

**ប្រការ៩.**- រាល់ការដឹកជញ្ជូនគ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះពីកន្លែងមួយទៅកាន់កន្លែងមួយផ្សេងទៀត ត្រូវសុំអាជ្ញាប័ណ្ណអនុញ្ញាតពីអគ្គស្នងការដ្ឋាននគរបាលជាតិ តាមរយៈនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និង អគ្គីភ័យ ដើម្បីចាត់វិធានការ ការពារសុវត្ថិភាពដល់គោលដៅ ។

**ប្រការ១០.**- គ្រប់ការដ្ឋាន អាជីវកម្ម សិប្បកម្ម និង បណ្តាអង្គការដែលប្រើប្រាស់គ្រឿងផ្ទុះ ជាតិផ្ទុះ សារធាតុផ្ទុះ ត្រូវធ្វើប្រវត្តិរូបសង្ខេប ភ្ជាប់ជាមួយ នូវ លិខិតថ្កោលទោស អ្នកបច្ចេកទេសបន្ទុះ រួមទាំង របាយការណ៍អំពីចំនួន បុគ្គលិក កម្មករ ផ្ញើមកនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និង អគ្គិភ័យ តាមកាលកំណត់ ។

**ប្រការ១១.**- អគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានរដ្ឋបាល ក្រុមអ្នកច្បាប់ អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល - គ្រប់សាលាខេត្ត- ក្រុង និង អង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខា និង ឡាយព្រះហស្តលេខា នេះតទៅ ។

ភ្នំពេញ.ថ្ងៃទី.........................ឆ្នាំ២០០៤



***ចំលងជូន :***

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួងស្ថាប័នចំណុះរាជរដ្ឋាភិបាល

-ដូចប្រការ ១១

- ឯកសារ- កាលប្បវត្តិ